ក្រសួង.ដ.ន.ស.
ចូល
លេខ 3009
ថ្ងៃខែឆ្នាំ 05-07-19 18:18
បញ្ជូន

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី

លេខ : ៨៤៨ សជណ

ថ្ងៃសុក្រ ៤កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែកក្កដា ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**ជម្រាបជូន**

- **ឯកឧត្ដមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់**
- **ឯកឧត្ដមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម**
- **ឯកឧត្ដមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**
- **ឯកឧត្ដមរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**
- **ឯកឧត្ដមរដ្ឋមន្ត្រីក្រសួងព័ត៌មាន**

**កម្មវត្ថុ៖** ករណីសំណើសុំគោលការណ៍សម្រេចលើវិធានការចាំបាច់សំដៅទប់ស្កាត់ការដ្ឋានសំណង់ខុសច្បាប់ ដើម្បីធានាអាយុជីវិតមនុស្ស ទ្រព្យសម្បត្តិ សុវត្ថិភាព និងគុណភាពសំណង់ទូទាំងប្រទេស។

**យោង ៖**
- លិខិតលេខ១៩៨១ ដនស/អរប. ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- លិខិតលេខ៤២៧ ខន/០១៩ សជណ ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៩ របស់ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្ដីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្ដមជ្រាបថា រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវវិធានការចាំបាច់មួយចំនួន ចំពោះការដ្ឋានសំណង់សណ្ឋាគារ អគារស្នាក់នៅរួម អគារពាណិជ្ជកម្ម អគាររោងចក្រ អគារសិប្បកម្ម និងសំណង់ផ្សេងទៀត ដែលគ្មានលិខិតអនុញ្ញាតនិង/ឬសាងសង់ខុសលក្ខណៈបច្ចេកទេសលើកលែងតែសំណង់លំនៅឋានផ្ទាល់ខ្លួនរបស់ប្រជាពលរដ្ឋដូចខាងក្រោម៖

១. ក្រសួងរ៉ែ និងថាមពល ចាត់វិធានការមិនឱ្យមានការផ្គត់ផ្គង់ថាមពលអគ្គិសនីដល់ការដ្ឋានសំណង់។

២. ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ចាត់វិធានការមិនឱ្យមានការផ្គត់ផ្គង់ទឹកស្អាតដល់ការដ្ឋានសំណង់។

៣. ក្រសួងសាធារណការ និងដឹកជញ្ជូន មិនត្រូវអនុញ្ញាតឱ្យតភ្ជាប់លូចូលបណ្ដាញលូសាធារណៈ។

៤. ក្រសួង ស្ថាប័ន និងអង្គភាពមានសមត្ថកិច្ច មិនត្រូវផ្ដល់លិខិតអនុញ្ញាតឱ្យប្រកបអាជីវកម្ម។

៥. ក្រសួងព័ត៌មាន និងអង្គភាពមានសមត្ថកិច្ច មិនត្រូវអនុញ្ញាតឱ្យផ្សព្វផ្សាយពាណិជ្ជកម្ម។

អាស្រ័យដូចបានជម្រាបជូនខាងលើសូមឯកឧត្តមជ្រាបនិងចាត់ចែងអនុវត្ត។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

**ចម្លងជូន៖**

- ក្រសួង ស្ថាប័ន និងអង្គភាពមានសម្ថតកិច្ច
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- រដ្ឋបាលរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ